**សុន្ទរកថាបិទកម្មវិធី**
**របស់ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ក្នុងពិធីប្រារព្ធខួបឆ្នាំទី ៥០ នៃការបង្កើតធនាគារអភិវឌ្ឍន៍អាស៊ី (ADB)**
**វេទិកាពិភាក្សាកម្រិតជាន់ខ្ពស់ស្តីពី**
**"ភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការអភិវឌ្ឍនៅកម្ពុជា"**

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦

*- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ  ជាទីគោរពដ៏ខ្ពង់ខ្ពស់*
*- លោកជំទាវ Noriko Ogawa អគ្គនាយករងធនាគារអភិវឌ្ឍន៍អាស៊ី ទទួលបន្ទុកតំបន់អាស៊ីភាគអាគ្នេយ៍*
*- លោក Samiuela T. Tukuafu, នាយកស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា*
*- សហសេវិក នៃរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី*
*- ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី*

នាពេលនេះ វេទិកាពិភាក្សាកម្រិតខ្ពស់ស្តីពី "**ភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការអភិវឌ្ឍនៅកម្ពុជា**" បានឈានមកដល់ទីបញ្ចប់ហើយ។ ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ថា វេទិកានេះបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។ តាំងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅ និងស្មោះស្ម័គ្រជូនចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម និងយកចិត្តទុកដាក់នៅក្នុងវេទិកាពិភាក្សាកម្រិតខ្ពស់នេះ។ ទន្ទឹមនេះ ខ្ញុំក៏សូមកោតសរសើរ និងថ្លែងអំណរគុណចំពោះសហសេវិកនៃធនាគារអភិវឌ្ឍន៍អាស៊ី ក៏ដូចជាក្នុងរាជរដ្ឋាភិបាល ដែលបានរួមសហការរៀបចំវេទិកាដ៏សំខាន់នេះផងដែរ។ បន្ថែមលើអ្វីដែលត្រូវបានលើកឡើងនៅក្នុងវេទិកាពិភាក្សានាព្រឹកនេះ ខ្ញុំសូមអនុញ្ញាតគូសរំលេចបន្ថែមដោយសង្ខេបនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមវិស័យគន្លឹះមួយចំនួននៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដូចតទៅ÷

**ទី១- វឌ្ឍនភាពនៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជា÷** ពិនិត្យជារួម សេដ្ឋកិច្ចកម្ពុជាសម្រេចបាននូវកំណើនគួរជាទីមោទនៈក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ កំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំរបស់កម្ពុជាក្នុងឆ្នាំ២០១៤-២០១៥ សម្រេចបានក្នុងរង្វង់ ៧% ស្របតាមគោលដៅកំណើនក្នុងរយៈពេលមធ្យមដែលរាជរដ្ឋាភិបាលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ២០១៤-២០១៨។ ទន្ទឹមនេះ សម្រាប់ឆ្នាំ២០១៦ និងឆ្នាំ២០១៧ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងមានកំណើនប្រមាណជា ៧%។ យ៉ាងណាមិញ ស្ថានភាពមិនសូវល្អនៃសេដ្ឋកិច្ចពិភពលោក និងនិន្នាការថមថយនៃកំណើនសេដ្ឋកិច្ចតំបន់ គួបផ្សំនឹងកំណើនយឺតនៃវិស័យកសិកម្មកម្ពុជា កំពុងស្ថិតនៅ

ជាបញ្ហាប្រឈមមួយសម្រាប់កិច្ចប្រឹងប្រែងដើម្បីសម្រេចបាននូវទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៦ និងឆ្នាំ២០១៧។ ក្នុងបរិការណ៍នេះ ដើម្បីធានាបាននូវភាពរឹងមាំនៃសេដ្ឋកិច្ច, រាជរដ្ឋាភិបាលនឹងបន្តតាមដានយ៉ាងប្រុងប្រយ័ត្ន និងដិតដល់បំផុតចំពោះហានិភ័យដែលអាចប៉ះពាល់ដល់ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាការរៀបចំនូវគោលនយោបាយអាទិភាពរយៈពេលមធ្យមមួយចំនួនផងដែរ ដែលរួមមាន៖ ការធានាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការគ្រប់គ្រងដោយប្រុងប្រយ័ត្នលើកំណើនឥណទាន, ការបង្កើនលំហថវិកាដើម្បីបំពេញតម្រូវការអភិវឌ្ឍន៍ប្រទេស, ការពង្រឹងភាពប្រកួតប្រជែងសេដ្ឋកិច្ចរបស់កម្ពុជា (ដែលរួមបញ្ចូលនូវការបន្តការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥) និងការធ្វើឱ្យវិស័យកសិកម្មមានកំណើនល្អឡើងវិញ។

**ទី២- វិស័យអប់រំ៖** ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលយល់ច្បាស់ថា ការអប់រំប្រកបដោយគុណភាពខ្ពស់ គឺជាកត្តាកំណត់ភាពជោគជ័យនៃការកសាងភាពខ្លាំងរឹងមាំនៃសេដ្ឋកិច្ចជាតិ។ តាមរយៈនេះ កម្ពុជាត្រូវការជាចាំបាច់នូវធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ, គំនិតច្នៃប្រឌិត និងកម្រិតជំនាញខ្ពស់, ទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត, ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងជាអន្តរជាតិ, ស្វែងរកកាលានុវត្តភាពក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ, និងធានាបាននូវនិរន្តរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ជាការពិត, វិស័យអប់រំនៅកម្ពុជាមានការរីកចម្រើនគួរជាទីមោទនៈ ទាំងផ្នែកបរិមាណ និងគុណភាព ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំដ៏ច្រើនថែមទៀត។ ទាំងនេះ ស្តែងឱ្យឃើញតាមរយៈការខិតខំសម្រេចបាននូវវឌ្ឍនភាពលើការអនុវត្តគោលនយោបាយទាំងបីក្នុងវិស័យអប់រំ រួមមាន៖ (១) ការធានាលទ្ធភាព ទទួលបាននូវសេវាអប់រំប្រកបដោយសមធម៌ (២) ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការសិក្សា និង (៣) ការធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ក្នុងទិសដៅឆ្លើយតបទៅនឹងចរន្តនៃការវិវត្តក្នុងតំបន់ និងពិភពលោក រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យថ្មីសម្រាប់អប់រំជាតិ និងសកលឆ្នាំ២០៣០ គឺការធានាឱ្យបាននូវការអប់រំប្រកបដោយគុណភាព, សមធម៌, បរិយាប័ន្ន, និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា សំដៅបណ្តុះបណ្តាលជំនាញ និងសមត្ថភាពធនធានមនុស្សដែលឆ្លើយតបប្រកបដោយប្រសិទ្ធភាព ទៅនឹងស្ថានភាពវិវត្តនៃទីផ្សារ និងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។

**ទី៣-វិស័យដឹកជញ្ជូន៖** ស្របគ្នានឹងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងអប់រំ ប្រព័ន្ធដឹកជញ្ជូននៅកម្ពុជាកំពុងបន្តរីកចម្រើនជាលំដាប់ ទាំងវិសាលភាព, ទំហំប្រតិបត្តិការ និងសេវា។ វិស័យដឹកជញ្ជូនបានដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រពាណិជ្ជកម្ម, ការវិនិយោគ និងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅកម្ពុជាស្ទើរគ្រប់វិស័យ ពោលគឺ ជាបណ្តាញតភ្ជាប់សសៃឈាមសេដ្ឋកិច្ចផ្ទៃក្នុងកម្ពុជា ក៏ដូចជាភ្ជាប់កម្ពុជាទៅនឹងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ ជាក់ស្តែង, ពាណិជ្ជកម្ម និងការវិនិយោគក្នុងវិស័យកសិកម្ម, វិស័យសំណង់, វិស័យកាត់ដេរ, វិស័យទេសចរណ៍ ជាដើម គឺសុទ្ធតែពឹងផ្អែកយ៉ាងខ្លាំងលើការដឹកជញ្ជូន ដែលរួមមានទាំងការដឹកជញ្ជូនតាមផ្លូវថ្នល់, ផ្លូវទឹក, ផ្លូវដែក, ផ្លូវអាកាសក្នុងស្រុក និងក្រៅស្រុក។ សមត្ថភាពនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តទន់ខ្សោយនឹងនាំឱ្យមានភាពយឺតយ៉ាវ និងចំណាយខ្ពស់ក្នុងការដឹកជញ្ជូន ព្រមទាំងកាត់បន្ថយការវិនិយោគលើគ្រប់វិស័យ ជាពិសេស នៅតំបន់ដាច់ស្រយ៉ាលដែលគ្មានការតភ្ជាប់ ដែលនេះជាឧបសគ្គរារាំងដល់ការអភិវឌ្ឍប្រទេសជាតិ។ ដើម្បីឆ្លើយតបជម្នះនឹងឧបសគ្គនេះ រាជរដ្ឋាភិបាលត្រូវធានាឱ្យបាននូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹងមាំ តាមរយៈការរៀបចំ និងការអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកពហុ-

មធ្យោបាយ ដែលត្រូវបានកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការចូលរួមពីវិស័យឯកជនក្នុងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដើម្បីធានាបាននូវភាពសំបូរបែបនៃការដឹកជញ្ជូន ប្រកបដោយបច្ចេកវិទ្យាទំនើប, នវានុវត្តភាព, ប្រសិទ្ធភាព និងសក្តិសិទ្ធភាពកម្រិតខ្ពស់។

ជារួម ការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន នឹងនៅតែបន្តស្ថិតនៅជាអាទិភាពដ៏ចម្បងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា។

**ទី៤- វិស័យកសិកម្ម÷** រាជរដ្ឋាភិបាលនៅតែចាត់ទុកថា កសិកម្មគឺជាវិស័យអាទិភាពខ្ពស់បំផុតមួយ ដែលបានរួមចំណែកក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា, ការធ្វើពិពិធភាវូបនីយកម្មមូលដ្ឋានសេដ្ឋកិច្ចជាតិ, ការធានាសន្តិសុខស្បៀង និងការលើកកម្ពស់ជីវភាពរបស់ប្រជាជន។ ក្នុងឆ្នាំ២០០៨-២០១៣ វិស័យកសិកម្មកម្ពុជាមានកំណើនជាមធ្យម ៤,៥% ក្នុងមួយឆ្នាំ និងរួមចំណែកប្រមាណ ២៩% នៃផសស។ ដោយមើលឃើញពីសារៈសំខាន់នៃវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញជាកញ្ចប់គោលនយោបាយ ដែលមានលក្ខណៈជាប្រព័ន្ធ ស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នា រួមមាន ការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាតាមអភិក្រមថ្មី ទាំងវិសាលភាព និងសន្ទុះ ដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម (បើកទូលាយ) ពោលគឺពឹងផ្អែកជាសំខាន់លើធនធានដែលមានស្រាប់ (ធនធានដី និងធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ទៅជាវិធីសាស្រ្តប្រពលកម្មដែលមានការអភិវឌ្ឍន៍ខ្ពស់។ វិធីសាស្រ្តនេះ គឺពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាទំនើប, ការស្រាវជ្រាវ និងការអភិវឌ្ឍ, កាអនុវត្តយន្តូបនីយកម្ម, ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាពកសិកម្ម និងពិពិធភាវូបនីយកម្មមុខដំណាំ ឱ្យក្លាយជាផលិតផលកសិកម្មដែលមានតម្លៃ និងតម្រូវការខ្ពស់ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃពាណិជ្ជូបនីយកម្ម។

**ទី៥- វិស័យធនាគារ÷** ក្នុងវិស័យធនាគារ កម្ពុជាក៏សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ផងដែរ ចាប់ពីឆ្នាំ២០០១ ដល់ឆ្នាំ២០១៥។ ជាក់ស្តែង ការផ្តល់ឥណទានដល់វិស័យឯកជនបានកើនដល់ ៦២,៧% នៃផសស ក្នុងឆ្នាំ២០១៥ ធៀបនឹង ៦,០% នៃ ផសស ក្នុងឆ្នាំ២០០១ និងប្រាក់បញ្ញើសរុបបានកើនដល់ ៥៨,៥% នៃផសស ក្នុងឆ្នាំ២០១៥ ធៀបនឹង ១០,៤% នៃផសស ក្នុងឆ្នាំ២០០១។ ទន្ទឹមនេះ ចំនួនធនាគារពាណិជ្ជកំពុងដំណើរការនៅកម្ពុជាបានកើនពី ៣១ នៅឆ្នាំ២០១១ ទៅ ៣៦ នៅឆ្នាំ២០១៥ និងចំនួនធនាគារឯកទេសបានកើនពី ៧ នៅឆ្នាំ២០១១ ដល់ ១១ នៅឆ្នាំ២០១៥។ ជាមួយគ្នានេះ ឥណទានខ្នាតតូចក៏មានការរីកចម្រើនផងដែរ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការអភិវឌ្ឍនៃវិស័យធនាគារ ត្រូវបានទទួលការគាំទ្រពីការកែទម្រង់ទីផ្សារហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា តាំងពីឆ្នាំ២០០១ មកម្ល៉េះ។ ជាទិសដៅ រាជរដ្ឋាភិបាលនឹងបន្តរក្សាស្ថិរភាពហិរញ្ញវត្ថុ ជាពិសេស ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីពង្រីកការផ្តល់សេវាហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយ ស្របតាមតម្រូវការទីផ្សារ តាមរយៈការបន្តជំរុញអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុកម្ពុជា ក្នុងនោះរួមទាំងការរៀបចំបង្កើតយុទ្ធសាស្រ្តជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុកម្ពុជាផង។

**ទី៦- វិស័យឯកជន៖** ជាការពិតណាស់ វិស័យឯកជនដែលត្រូវបានរាជរដ្ឋាភិបាលបន្តចាត់ទុកជា “ក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច” មានតួនាទីគន្លឹះក្នុងការជំរុញកំណើន និងការអភិវឌ្ឍសង្គម ទាំងក្នុងវិស័យសេដ្ឋកិច្ច, ហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ ក្នុងឆ្នាំ២០១១ វិស័យឯកជនបានស្រូបយក ៩១% នៃចំនួនអ្នកធ្វើការសរុបនៅក្នុងសហគ្រាសដែលមានចំនួន ១,៦៧ លាននាក់ និងតំណាងឱ្យ ៩៧% នៃចំនួនសហគ្រាសសរុបនៅកម្ពុជា។ ដើម្បីបង្កើនសក្តានុពលនៃវិស័យឯកជន ក្នុងការចូលរួមអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលនឹងបន្ត៖ (១) ជំរុញការកែលម្អយន្តការស្ថាប័ន, ក្របខ័ណ្ឌគតិយុត្ត និងនិយ័ត្តកម្មសម្រាប់ការរីកលូតលាស់នៃវិស័យឯកជន ដោយបន្តធ្វើឱ្យកាន់តែប្រសើរនូវការសម្រួលពាណិជ្ជកម្ម និងការវិនិយោគ; (២) ពង្រឹងយន្តការវេទិការាជរដ្ឋាភិបាល និងវិស័យឯកជនដើម្បីដោះស្រាយបញ្ហាដែលជាកង្វល់រួមឱ្យមានប្រសិទ្ធភាព និង (៣) លើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ, វិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម និងវិស័យអាទិភាពផ្សេងទៀត តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលយន្តការនេះមិនត្រឹមតែនាំមកនូវប្រភពទុនហិរញ្ញប្បទានបន្ថែមប៉ុណ្ណោះទេ តែលើសពីនេះក៏នាំមកនូវចំណេះដឹង-ចំណេះធ្វើ, បច្ចេកវិទ្យាទំនើប និង នវានុវត្តភាព ជាប្រយោជន៍ដល់ការពង្រឹងប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិផងដែរ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!**

ដូចដែលឯកឧត្តម, លោកជំទាវ, អស់លោក, លោកស្រី បានជ្រាបស្រាប់ហើយថា ក្នុងទសវត្សរ៍ចុងក្រោយនេះ បើទោះបីជាសេដ្ឋកិច្ចកម្ពុជាបានទទួលរងនូវផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោកក្តី, កម្ពុជានៅតែសម្រេចបាននូវសមិទ្ធផលល្អប្រសើរ ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនគួរឱ្យកត់សម្គាល់។ បើគ្មានកិច្ចសហប្រតិបត្តិការទាន់ពេលវេលារបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងទៀតនោះទេ សមិទ្ធិផលដ៏ធំធេងទាំងនេះ ពិតជាមិនអាចសម្រេចបានឡើយ។ ក្នុងន័យនេះ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ ដែលបានជួយគាំទ្រដល់កម្ពុជាក្នុងដំណើរឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមមួយ ប្រកបដោយចីរភាព និងបរិយាប័ន្ន។ ខ្ញុំជឿជាក់ថា វេទិកាដ៏កម្រនាថ្ងៃនេះ មិនត្រឹមតែជាការអបអរសាទរខួបឆ្នាំទី៥០ នៃការបង្កើតធនាគារអភិវឌ្ឍន៍អាស៊ីប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងជាការត្រួតពិនិត្យឡើងវិញ និងជាឱកាសមួយសម្រាប់ពិភាក្សាយ៉ាងទូលំទូលាយ លើវិស័យពាក់ព័ន្ធ ដើម្បីប្រមូលមតិយោបល់និងបទពិសោធន៍ ដែលជាធាតុចូលបន្ថែមយ៉ាងសំខាន់ ក្នុងការរៀបចំពង្រឹងភាពជាដៃគូរបស់យើងសំដៅធានានូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះបញ្ហាប្រឈមនានាក្នុងពេលបច្ចុប្បន្ន ក៏ដូចជាការរៀបចំផែនការអភិវឌ្ឍន៍នាពេលអនាគត ក្នុងទិសដៅសម្រេចឱ្យបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ពោលគឺ ការប្រែក្លាយខ្លួនទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងបន្តឈានឡើងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ជាមួយគ្នានេះ ខ្ញុំក៏មានជំនឿយ៉ាងមុតមាំថា ធនាគារអភិវឌ្ឍន៍អាស៊ីពិតជានឹងបន្តគាំទ្រដល់កម្ពុជាថែមទៀត ដើម្បីឱ្យកម្ពុជាសម្រេចបាននូវចក្ខុវិស័យអភិវឌ្ឍន៍របស់ខ្លួន ដោយមិនធ្លាក់ជាប់ក្នុងអន្ទាក់នៃប្រទេសមានចំណូលមធ្យមឡើយ។

នៅទីបញ្ចប់ ជាមួយនឹងការអបអរសាទរនូវការប្រារព្ធខួបឆ្នាំទី៥០ នៃការបង្កើតធនាគារអភិវឌ្ឍន៍អាស៊ី នាពេលនេះ ខ្ញុំសូមគោរពជូនពរចំពោះឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់**, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ, គណៈគ្រប់គ្រង និងបុគ្គលិកដែលបម្រើការងារនៅធនាគារអភិវឌ្ឍន៍អាស៊ី, សហសេវិក នៃរាជរដ្ឋាភិបាល និងអង្គវេទិកាទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណយ៉ាងជ្រាលជ្រៅ និងសូមប្រកាសបិទកម្មវិធីនាពេលនេះ** !